# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ១១២៨ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល
- បានឃើញសេចក្តីសម្រេចលេខ១០សសរ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៩ ស្តីពីការកែសម្រួលគណៈកម្មការជាតិរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-លោកជំទាវ **អ៊ុត សោភា** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៣-ឯកឧត្តម **ភឹមរ័ត្ន ចិសិដ្ឋ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានប្រចាំការ |
| ៤-ឯកឧត្តម **ប៊ុន ហុន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥-ឯកឧត្តម **ហែម ក្រាញ់តូនី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |

៦-តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
៧-តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
៨-តំណាងក្រសួងព័ត៌មាន សមាជិក
៩-តំណាងក្រសួងសុខាភិបាល សមាជិក
១០- តំណាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក
១១- តំណាងក្រសួងទេសចរណ៍ សមាជិក
១២- តំណាងគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
១៣- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
១៤- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ សមាជិក
១៥- អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ សមាជិក
១៦- អភិបាលនៃគណៈអភិបាលខេត្តសៀមរាប សមាជិក
១៧- តំណាងសហភាពសហព័ន្ធយុវជនកម្ពុជា សមាជិក
១៨- តំណាងអង្គការសង្គមស៊ីវិលកម្ពុជា សមាជិក។

**ប្រការ២ .-**

ក្រុមការងារអន្តរក្រសួងនេះ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ ចាត់ចែង និងសម្របសម្រួលជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីរៀបចំវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០
- រៀបចំកិច្ចប្រជុំពិភាក្សា ត្រួតពិនិត្យខ្លឹមសារ រៀបចំឯកសារ រៀបចំការសម្តែងសិល្បៈ និងរៀបចំដំណើរទស្សនកិច្ចសម្រាប់ភ្ញៀវអន្តរជាតិដែលអញ្ជើញមកចូលរួមវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០
- រៀបចំគម្រោងចំណាយនិងកិច្ចការហិរញ្ញកិច្ចសម្រាប់ដំណើរការកម្មវិធីទាំងមូល
- សម្របសម្រួលក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសង្គ្រោះបន្ទាន់
- ធ្វើទំនាក់ទំនងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ដើម្បីអញ្ជើញភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ និងអង្គទូត មកចូលរួមវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០
- ត្រូវពិគ្រោះយោបល់ជាមួយអនុគណៈកម្មការសម្របសម្រួលការរៀបចំព្រឹត្តិការណ៍ក្រៅកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ នៃគណៈកម្មការជាតិរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០ និងជាមួយគណៈកម្មការជាតិនេះ អំពីការងារដែលពាក់ព័ន្ធចាំបាច់នានា
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

ត្រូវបានប្រគល់ភារកិច្ចជូនវេទិកាសម្ព័ន្ធសង្គមស៊ីវិល បំពេញតួនាទីជាលេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០។

លេខាធិការដ្ឋាននេះ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- បំពេញការងារជាសេនាធិការជូនក្រុមការងារអន្តរក្រសួង ក្នុងការទំនាក់ទំនងជាមួយក្រសួង ស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិពាក់ព័ន្ធ ដើម្បីរៀបចំដំណើរការការងារឱ្យបានរលូន មានប្រសិទ្ធភាព និងជោគជ័យ
- សហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នជាតិ និងស្ថាប័នអន្តរជាតិពាក់ព័ន្ធ ក្នុងដំណើរការរៀបចំវេទិកាប្រជាជនអាស៊ី-អឺរ៉ុបឆ្នាំ២០២០ និងការអញ្ជើញភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ និងអង្គទូត និង
- ទទួលភារកិច្ចផ្សេងទៀត ដែលប្រធានក្រុមការងារប្រគល់ជូន។

ចំពោះសមាសភាពអនុប្រធាននិងសមាជិកនៃលេខាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានក្រុមការងារអន្តរក្រសួង តាមការស្នើសុំរបស់ប្រធានលេខាធិការដ្ឋាន។

**ប្រការ៤ .-**

ក្រុមការងារអន្តរក្រសួងនេះមានសិទ្ធិបង្កើតអនុក្រុមការងារតាមការចាំបាច់ តាមរយៈសេចក្ដីសម្រេចរបស់ប្រធានក្រុមការងារអន្តរក្រសួង។

**ប្រការ៥ .-**

ក្រុមការងារអន្តរក្រសួងនេះមានសិទ្ធិអញ្ជើញឥស្សរជនជាតិនិងអន្តរជាតិ មកចូលរួមពិគ្រោះយោបល់ និងផ្លាស់ប្ដូរបទពិសោធន៍ដែលពាក់ព័ន្ធនឹងការរៀបចំវេទិកាប្រជាជនអាស៊ី-អឺរ៉ុប។

**ប្រការ៦ .-**

ក្រុមការងារអន្តរក្រសួងនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី សម្រាប់ដំណើរការការងាររបស់ខ្លួន។

ក្រុមការងារអន្តរក្រសួងនេះត្រូវប្រើប្រាស់កញ្ចប់ថវិការបស់រាជរដ្ឋាភិបាល ដែលត្រូវស្នើតាមរយៈគណៈកម្មការជាតិរៀបចំកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ឆ្នាំ២០២០ សម្រាប់ការបំពេញការងាររបស់ខ្លួន។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៤ កើត ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមករា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ